**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## សូមគោរពជូន
## សម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ
## នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ គៅ គឿន ទៀបាញ់
## ក្នុងឱកាសអបអរសាទរខួប ៥០ឆ្នាំ នៃចំណងអាពាហ៍ពិពាហ៍

***សម្តេចពិជ័យសេនា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏មហាសោមនស្សរំភើបរីករាយ ក្នុងឱកាសអបអរសាទរខួប ៥០ឆ្នាំ នៃចំណងអាពាហ៍ពិពាហ៍ របស់ **សម្តេចពិជ័យសេនា** និង**លោកជំទាវ** នាពេលខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមសម្តែងនូវកតញ្ញុតាធម៌ និងសេចក្តីអំណរសាទរយ៉ាងជ្រាលជ្រៅជាទីបំផុត និងសូមជូនពរបវរមហាប្រសើរថ្លៃថ្លា ជូន **សម្តេចពិជ័យសេនា** និង**លោកជំទាវ** សូមប្រកបដោយសេចក្តីសុខសុភមង្គល និងទទួលបាននូវសុខភាពល្អបរិបូរ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រចំពោះគំរូវីរភាពដ៏មោះមុត និងការចូលរួមចំណែកយ៉ាងធំធេងរបស់ **សម្តេចពិជ័យសេនា** និង**លោកជំទាវ** ប្រកបដោយឆន្ទៈមនសិការស្នេហាជាតិ និងប្រជាជន ទាំងក្នុងវិស័យពុទ្ធចក្រ និងអាណាចក្រ ដើម្បីបម្រើឧត្តមប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ និងការការពារសុខសន្តិភាព ឯករាជ្យភាព បូរណភាពទឹកដី ឱ្យទទួលបាននូវភាពសុខដុមរមនា ប្រជាពលរដ្ឋរស់នៅប្រកបដោយសេចក្តីសុខសុភមង្គល និងមានការអភិវឌ្ឍរីកចម្រើននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ឆ្នាំម្សាញ់ ព្រះនាមគោរាគៈទេវី ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល ជូនចំពោះ **សម្តេចពិជ័យសេនា** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ គៅ គឿន ទៀបាញ់** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០២៥
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**